# បទពិសោធន៍របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងដំណើរសួរដេញដោលសាក្សី ឈូក រិន

## (ចាន់ ប្រាថ្នា)

នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកសវនាការស្តាប់សក្ខីកម្មរបស់អតីតកម្មាភិបាលខ្មែរក្រហម និងជាទណ្ឌិតឈ្មោះ ឈូក រិន ដែលជាមនុស្សជំនិតរបស់ ឈិត ជឿន ហៅ ម៉ុក និង ផ្តល់សក្ខីកម្មយ៉ាងច្រើនអំពី នួន ជា ពាក់ព័ន្ធនឹងការសម្រេចបោសសម្អាតកម្មាភិបាលនៅភូមិភាគបូព៌ា ។ ក្នុងរយៈពេលមួយម៉ោងកន្លះដំបូង សវនាការបានប្រព្រឹត្តទៅក្នុងស្ថានភាពយ៉ាងលំបាក ស្ទើរតែគ្មានដំណោះស្រាយនៅចំពោះមុខសាធារណជនប្រមាណជាង៥០០ នាក់នៅក្នុងសាលសវនាការ និងសាធារណជនទូទៅដែលកំពុងតាមដានសវនាការតាមរយៈការផ្សាយបន្តផ្ទាល់របស់ទូរទស្សន៍ ស៊ី.អិន.ស៊ី ។ អង្គជំនុំជម្រះបានបដិសេធសំណើរបស់ ឈូក រិន ដែលបានសុំម្តងហើយម្តងទៀតឲ្យផ្អាកសវនាការ ដោយសារខ្លួនមានបញ្ហាសុខភាពពុំអាចផ្តល់សក្ខីកម្មបាន ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះបានបន្ទាប់ជាច្រើនដងដល់ ឈូក រិន ឲ្យឆ្លើយតបសំណួររបស់តំណាងសហព្រះរាជអាជ្ញានៅខណៈពេលដែលសាក្សីរូបនេះស្នើសុំមិនឆ្លើយតបសំណួរ និងបង្ហាញជំហរថា ខ្លួននឹងឆ្លើយសំណួរទាំងអស់នៅពេលណាដែលសុខភាពរបស់ខ្លួនមានភាពល្អប្រសើរអាចផ្តល់សក្ខីកម្មបាន ។ ចុងក្រោយអង្គជំនុំជម្រះបដិសេធនូវការផ្តល់យោបល់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា គឺលោក សុន អរុណ ដែលថាអង្គជំនុំជម្រះគប្បីផ្អាកសវនាការជាបណ្តោះអាសន្ន ។

ទោះបីជាមានការបន្ទាប់ដូច្នេះក្តី ឈូក រិន នៅតែបន្តស្នើសុំមិនឆ្លើយសំណួររបស់តំណាងសហព្រះរាជអាជ្ញាដដែល ។ បន្ថែមលើនេះ ឈូក រិន បានប្រើពាក្យពេចន៍បញ្ចិតបញ្ចៀងមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ ដោយបានលើកឡើងថា « សម័យខ្មែរក្រហម ពល ពត និង នួន ជា ប្រើទាំងឈើក៏ខ្ញុំធ្វើដែរព្រោះខ្លាចស្លាប់ ។ ប៉ុន្តែពេលនេះខ្ញុំស្នើសុំឲ្យតុលាការចាត់តាំងពេទ្យឲ្យពិនិត្យរូបខ្ញុំសិន» ។ ឈូក រិន បានបញ្ជាក់ថា ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ សុខភាពរបស់ខ្លួនគឺមានការធ្លាក់ចុះយ៉ាងខ្លាំង ព្រោះនៅក្នុងមន្ទីរឃុំឃាំងខ្លួនពុំទទួលបានអាហារគ្រប់គ្រាន់ ដែលបណ្តាលឲ្យខ្សោយ និងឈឺក្បាលខ្លាំង ។ ភ្នែកទាំងពីរមានការក្រហាយ និងហូរទឹកភ្នែកនៅពេលបើកភ្នែកម្តងៗ ដូច្នេះពុំអាចមើលអក្សរឲ្យបានច្បាស់ឡើយ ។

តាមការអនុវត្តកន្លងមក អង្គជំនុំជម្រះសាលាដំបូងពុំមានលក្ខណៈដូចអ្វីដែល ឈូក រិន បានចោទប្រកាន់ឡើយ ។ អង្គជំនុំជម្រះធ្លាប់បានសម្រេចផ្អាកសវនាការស្តាប់សក្ខីកម្មដ៏មានសារៈសំខាន់របស់អតីតកម្មាភិបាលខ្មែរក្រហមចំនួនពីររូបគឺ ឡុង ណារិន្ទ និង សួង ស៊ីគឿន ។ ក្នុងអំឡុងខែធ្នូ ឆ្នាំ២០១១

អង្គជំនុំជម្រះបានសម្រេចផ្អាកសវនាការស្តាប់សក្ខីកម្មរបស់ ឡុង ណូរិន្ទ (អតីតកម្មាភិបាលជាន់ខ្ពស់ម្នាក់ដែលបានបម្រើការងារនៅក្នុងក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្រោយមកក្នុងឆ្នាំ ១៩៩៤ ឡុង ណូរិន្ទ ត្រូវបានតែងតាំងជាអគ្គលេខាធិការនៃចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ដោយមាន អៀង សារី ជាប្រធាន) ហើយក្នុងអំឡុងខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានសម្រេចផ្អាកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី សួង ស៊ីគឿន (អតីតកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ម្នាក់ដែលបានបម្រើការងារនៅក្នុងក្រសួងការបរទេសដែរ ហើយក្រោយមកក្នុងឆ្នាំ ១៩៨១ សួង ស៊ីគឿន មានតួនាទីជាអ្នកតំណាងឲ្យរបបកម្ពុជាប្រជាធិបតេយ្យ ចរចារជាមួយសម្តេចព្រះបាទ នរោត្តម សីហនុ និង សឺន សាន ដើម្បីបង្កើតរដ្ឋាភិបាលត្រីភាគី) បន្ទាប់ពីសាក្សីទាំងពីររូបនេះបានស្នើសុំផ្អាក ។ អង្គជំនុំជម្រះពិនិត្យឃើញថាសាក្សីពិតជាមានបញ្ហាសុខភាពប្រាកដមែន ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានពន្យារពេលសវនាការជាច្រើនដងសម្រាប់ជនជាប់ចោទ នួន ជា និង អៀង សារី នៅខណៈពេលដែលជនជាប់ចោទទាំងពីររូបនេះមានបញ្ហាសុខភាពពុំអាចតាមដានសវនាការបាន ។ ជាងនេះទៅទៀត អង្គជំនុំជម្រះបានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យមានសេរីភាពរហូតមកដល់សព្វថ្ងៃនេះ បន្ទាប់ពីរកឃើញថា ជនជាប់ចោទរូបនេះមានសម្បទាពុំគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ នៅក្នុងសវនាការថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានធ្វើការណែនាំដល់ជនជាប់ចោទ នួន ជា នៅខណៈពេលដែលជនជាប់ចោទរូបនេះបានថ្លែងក្នុងន័យប្រមាថនៅចំពោះទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច ថា« គេមិនដែលយកឈើពុក ឈើរលួយ ឈើស្អុយ មកធ្លាក់ធ្វើព្រះមកទេសនាឲ្យពុទ្ធបរិស័ទនោះទេ» ។ នួន ជា បានដឹងយ៉ាងច្បាស់ថា ក្នុងអឡុងពេលនោះ ឌុច គឺជាទណ្ឌិតមួយរូបដែលត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។

បើពិនិត្យមើលស្ថានភាពរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលបច្ចុប្បន្ន ការពន្លឿនកិច្ចដំណើរការនីតិវិធីជំនុំជម្រះ គឺជាបញ្ហាចំបងមួយក្នុងចំណោមបញ្ហាសំខាន់ៗផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា និងបញ្ហាកង្វះខាតថវិការ ។ មួយរយៈកាលចុងក្រោយនេះ អង្គជំនុំជម្រះសាលាដំបូងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធ្វើយ៉ាងណាឲ្យកិច្ចដំណើរការជំនុំជម្រះលើសំណុំរឿង០០២ បានចប់សព្វគ្រប់ និង ប្រព្រឹត្តទៅដោយឆាប់រហ័ស ។ អង្គជំនុំជម្រះធ្លាប់បានសម្រេចបំបែកសំណុំរឿង០០២ ទៅជាផ្នែកតូចៗ ដើម្បីមានភាពងាយស្រួលក្នុងការជំនុំជម្រះ និងអាចចេញសាលក្រមសម្រេចសេចក្តីក្នុងរយៈពេលខ្លីមួយ ។ តាមរយៈការបំបែកសំណុំរឿងនេះទៀត អង្គជំនុំជម្រះបានឈានទៅដល់ការកាត់បន្ថយចំនួន ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ដែលគ្រោងនឹងកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខខ្លួន ។ ពោលគឺសម្រេចកោះហៅតែដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ឬអ្នកជំនាញណាដែលនឹងផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវ

យកមកសម្រេចសេចក្ដីនៅក្នុងតំណាក់កាលទីមួយតែប៉ុណ្ណោះ ។ ចំណែកអ្នកដែលមិនផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវយកមកជំនុំជម្រះក្នុងដំណាក់កាលដំបូងនេះ គឺអង្គជំនុំជម្រះនឹងមិនធ្វើការកោះហៅឡើយ ។ លើសពីនេះទៀត អង្គជំនុំជម្រះបានសម្រេចកាត់បន្ថយពេលវេលារបស់ភាគីក្នុងការសួរដេញដោលសាក្សី ដោយកំណត់ត្រឹមតែ ១ថ្ងៃ សម្រាប់ក្រុមមេធាវីការពារក្ដីជនជាប់ចោទទាំងពីររូប និង ១ថ្ងៃទៀត សម្រាប់តំណាងសហព្រះរាជអាជ្ញា និង ក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ។ ក្នុងការសួរដេញដោលនោះទៀតសោត អង្គជំនុំជម្រះជំរុញឲ្យភាគីទាំងអស់សួរបញ្ជាក់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុស្ដាប់ចម្លើយដែលសាក្សីធ្លាប់បានផ្ដល់ជូនអ្នកស៊ើបអង្កេតម្ដងរួចហើយ ដើម្បីធ្វើយ៉ាងណាឲ្យមានភាពឆាប់រហ័ស ។ ដូច្នេះពិតប្រាកដណាស់ដែលគោលបំណងនៃការចង់ពន្លឿនកិច្ចដំណើរការនីតិវិធីរបស់ខ្លួន គឺជាមូលហេតុនៃការបដិសេធសំណើរបស់ ឈូក រីន សុំឲ្យពន្យារពេលសវនាការ ។

មូលហេតុទី២ដែលពុំអាចកាត់ផ្ដាច់ចេញពីមូលហេតុទី១ខាងលើនោះគឺ អង្គជំនុំជម្រះទំនងជាកត់សម្គាល់ឃើញថា ស្ថានភាពសុខភាពរបស់ ឈូក រីន ក្នុងអំឡុងពេលនោះ គឺពុំទាន់ឈានទៅដល់ការសម្រេចផ្អាកសវនាការនូវឡើយ ឬ ជាចេតនាមួយរបស់សាក្សីដែលមិនព្រមសហការជាមួយតុលាការតែប៉ុណ្ណោះ ។ ឈូក រីន បានដើរចូលក្នុងបន្ទប់សវនាការ និងលើកដៃសំពះពីចម្ងាយក្នុងដំណើរយ៉ាងស្វាហាប់ ហើយបានឆ្លើយសំណួរបឋមមួយចំនួនរបស់អង្គជំនុំជម្រះ និងរៀបរាប់អំពីស្ថានភាពសុខភាព ព្រមទាំងសំណើរបស់ខ្លួនក្នុងទឹកមុខញញឹមរីករាយ ។ ភ្លាមនោះ ឈូក រីន ប្រែមកជាទឹកមុខស្រងូតស្រងាត់ សោះអង្គើយ ពុំចង់ស្ដី បន្ទាប់ពីសំណើសុំរបស់ខ្លួនត្រូវបានអង្គជំនុំជម្រះសម្រេចបដិសេធចោល ។ ប៉ុន្តែស្ថានភាពទាំងនេះបានធូរស្រាលមកវិញបន្ទាប់ពីមានរបាយការណ៍ពេទ្យបញ្ជាក់ថាស្ថានភាពជាក់ស្ដែងរបស់ ឈូក រីន គឺអាចចូលរួមស្ដាប់ និងឆ្លើយតបសំណួររបស់ភាគីនៅក្នុងសវនាការបាន ។ លើសពីនេះទៀត នៅពេលរសៀលក្នុងថ្ងៃដដែលនោះ និងម្សិលមិញ១ថ្ងៃពេញ(ថ្ងៃទី២៣) ឈូក រីន បានឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីក្ដីយ៉ាងក្បោះក្បាយដោយពុំបានសម្ដែងនូវអាការៈឈឺចាប់ ឬហត់នឿយឡើយ ។

## ដំណោះស្រាយបញ្ហាចំពោះមុខ

នៅក្នុងរយៈពេលជិតមួយម៉ោងកន្លះនោះ ឈូក រីន មិនព្រមឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាឡើយ ទោះបីសំណួរទាំងនោះមានភាពងាយៗក្នុងការឆ្លើយ ឬចម្លើយនៃសំណួរទាំងនោះមិននាំឲ្យដាក់បន្ទុកមកលើខ្លួនឯងក៏ដោយ ។ អង្គជំនុំជម្រះបានបញ្ជាក់ម្ដងហើយម្ដងទៀតអំពីការណីកិច្ចរបស់សាក្សីក្នុងការឆ្លើយសំណួររបស់ភាគី ប៉ុន្តែជាលទ្ធផល ឈូក រីន នៅតែបន្តបដិសេធមិនឆ្លើយតបសំណួរ ហើយទទូចសុំអង្គជំនុំជម្រះសម្រេចផ្អាកសវនាការ និងផ្ដល់ការព្យាបាលវេជ្ជសាស្ត្រដល់ខ្លួនរហូតមានសុខភាពល្អឡើងវិញដើម្បីអាចផ្ដល់សក្ខីកម្មបានពេញលេញ និងត្រឹមត្រូវ ។ បន្ថែមលើនេះ

ទៀត ឈូក រីន បានចោទប្រកាន់ថាអង្គជំនុំជម្រះ គ្មានព្រហ្មវិហារធម៌ទាំងបួន, ខ្វះក្ដីមេត្តា ករុណាចំពោះខ្លួន, មិនចាត់ទុកខ្លួនជាមនុស្ស គឺចាត់ទុកដូចជាសត្វ, ខ្ជះខ្ជាយពេលវេលា ។ល ។ ដែលអង្គជំនុំជម្រះចាត់ទុកថា គឺជាការប្រមាថដល់តុលាការ និងមិនគោរពករណីកិច្ចក្នុងការផ្ដល់សក្ខីកម្មក្នុងនាមជាសាក្សី ។ គួរបញ្ជាក់ថា ការចោទប្រកាន់របស់ ឈូក រីន ទាំងនេះ គឺធ្វើឡើងបន្ទាប់ពីលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយត៍ បង្គាប់ឲ្យ ឈូក រីន ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ដើម្បីជៀសវាងការធ្វើឲ្យខ្ជះខ្ជាយពេលវេលាឥតប្រយោជន៍ ។ លោកស្រីបានបញ្ជាក់ថា សំណួររបស់សហព្រះរាជអាជ្ញាគឺមានភាពងាយស្រួលក្នុងការឆ្លើយដោយពុំចាំបាច់ប្រើពេលគិតឡើយ ។ ក្នុងអំឡុងពេលនោះ ឈូក រីន បានប្រតិកម្មយ៉ាងខ្លាំង ហើយអះអាងថា អង្គជំនុំជម្រះគឺជាអ្នកធ្វើឲ្យខ្ជះខ្ជាយពេលវេលា គឺពុំមែនខ្លួនឡើយ ព្រោះខ្លួនបានសរសេរលិខិតសំណើសុំដូចគ្នានេះមកតុលាការជាយូរមកហើយ ប៉ុន្តែតុលាការមិនបានឆ្លើយតបអ្វីទាំងអស់ ។

តាមរយៈអាកប្បកិរិយារឹងរូស និង ការប្រមាថរបស់ ឈូក រីន មកលើអង្គជំនុំជម្រះនៅចំពោះមុខសាធារណជន ជននេះអាចប្រឈមនឹងការដាក់ទណ្ឌកម្ម ឬចំណាត់ការណាមួយដោយអង្គជំនុំជម្រះដូចជាសម្រេចបញ្ជូនខ្លួនទៅអាជ្ញាធរមានសមត្ថកិច្ចណាមួយដើម្បីចាត់ការតាមផ្លូវច្បាប់ ។[1] ទោះបីជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងទំនងជាអស់លទ្ធភាពក្នុងការចាត់វិធានការចំពោះសាក្សីរូបនេះទៀតហើយ ។ នៅចំពោះមុខ ឈូក រីន ប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម និល ណុន បានត្រឹមតែថ្លែងយ៉ាងខ្លីថា« *លោកមិនគ្រាន់តែមិនឆ្លើយនឹងសំណួរ លោកថែមទាំងប្រមាថដល់តុលាការទៀត ទំនងជាលោកអាងថាលោកជាប់ពន្ធនាគារអស់មួយជីវិតហើយ ហើយកំពុងតែអនុវត្តទោសទើងបានជាលោកប្រើពាក្យពេចន៍ដូច្នេះ...*» ។

ចុងក្រោយអង្គជំនុំជម្រះសាលាដំបូងនៅតែអាចរកដំណោះស្រាយបាន តាមរយៈការសម្រេចអនុញ្ញាតឲ្យភាគីទាំងអស់ដកស្រង់សក្ខីកម្មដែល ឈូក រីន ធ្លាប់បានផ្ដល់ជូនអ្នកស៊ើបអង្កេតមកសួរបញ្ជាក់ ទោះបីសាក្សីរូបនេះព្រម ឬមិនព្រមឆ្លើយតបក៏ដោយ ហើយបានចាត់ទុកថា នេះគឺជាទម្រង់មួយនៃការសួរដេញដោលចំពោះសាក្សី ឈូក រីន ។ (គួរកត់សម្គាល់ត្រង់ចំណុចនេះថា អង្គជំនុំជម្រះពុំបានបញ្ជាក់ឲ្យបានច្បាស់ថា តើសក្ខីកម្មដែលភាគីដកស្រង់មកសួរបញ្ជាក់ ប៉ុន្តែសាក្សីពុំបានឆ្លើយតបអ្វីសោះនោះ គឺត្រូវចាត់ទុកថាត្រឹមត្រូវ ឬមិនត្រឹមត្រូវ? ហើយចំណុចសំខាន់មួយទៀតនោះគឺ តើការអនុវត្តដូច្នេះអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់សាក្សីក្នុងការមិនផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងដែរឬទេ? បញ្ហានេះគប្បីមានការបញ្ជាក់ឲ្យបានច្បាស់ ដើម្បីអាចធ្វើជាយុត្តិសាស្ត្រសម្រាប់អនុវត្តនៅពេលក្រោយៗទៀត) ។

១ - សូមមើលវិធាន៣៥ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣

ចុងក្រោយអង្គជំនុំជម្រះបានបញ្ជាក់ថា “ភស្តុតាងអាចនឹងយកជាបានការ លុះត្រាតែលើកឡើងមកដាក់ដេញដោលនៅចំពោះមុខក្នុងសវនាការ ទើបវាមានតម្លៃជាភស្តុតាងដើម្បីពិនិត្យពិចារណាសម្រាប់សម្រេចសេចក្តី មិនមែនគ្រាន់តែយកមកដាក់ក្នុងសំណុំរឿង គឺមានតម្លៃនោះទេ ។ បើមានតម្លៃហើយ យើងពុំចាំបាច់ធ្វើសវនាការនាំតែខាតពេលធ្វើអ្វី” ។

បប់

**ដោយៈ ចាន់ ប្រាថ្នា**

**ពិនិត្យដោយ ឆាំង យុ និង វ៉ាន់ថាន់ ពៅដារ៉ា**